**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## តួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា(**គ.ជ.វ.**)។

# ជំពូកទី២

# តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាននៃគ.ទ.រ.

**មាត្រា២ ..**

ក្រសួងមុខងារសាធារណៈ ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃ**គ.ទ.រ.** ត្រូវបំពេញតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំនិងសម្របសម្រួលក្នុងការរៀបចំនិងស្នើនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការចាំបាច់នានា ព្រមទាំងកំណត់នូវក្របខណ្ឌសមិទ្ធកម្មដែលរួមមានសូចនាករ គោលដៅ និងវិធីសាស្ត្រវាស់វែងក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រីនិងស្ថាប័នតាមរយៈ (១)ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២)ការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង(៣)ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ដឹកនាំនិងសម្របសម្រួលអង្គភាពចំណុះក្រសួង ដើម្បីអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធានការនានាក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល
- រៀបចំយន្តការស្ថាប័នផ្ទៃក្នុងក្រសួង និងកំណត់បែបបទនិងនីតិវិធីដើម្បីធ្វើការតាមដានត្រួតពិនិត្យ វាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
- សម្របសម្រួល ផ្តល់ការតម្រង់ទិស ផ្តល់ការគាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានក្នុងក្របខណ្ឌនៃការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍ ដើម្បីជំរុញនិងគាំទ្រដល់ការរៀបចំនិងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រ វិធានការ និងផែនការសកម្មភាពក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល
- សហការនិងសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ក្នុងការរៀបចំនិងអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល
- ធានានូវការរៀបចំកិច្ចប្រជុំនានារបស់**គ.ទ.រ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូន**គ.ទ.រ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន**គ.ទ.រ.**។

**មាត្រា៣ ..**

ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃ **គ.ក.រ.** ក្រសួងមុខងារសាធារណៈត្រូវទទួលបន្ទុកដឹកនាំ និងសម្របសម្រួលអនុគណៈកម្មាធិការនិងក្រុមការងារផ្សេងៗ ពាក់ព័ន្ធនឹងការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដែលត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងរបៀបរបបការងាររបស់លេខាធិការដ្ឋាននៃគ.ក.រ.

**មាត្រា៤ ..**

រចនាសម្ព័ន្ធអង្គភាពចំណុះក្រសួងមុខងារសាធារណៈ ដែលរួមមានសាលាភូមិន្ទរដ្ឋបាល អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ត្រូវផ្ដល់ការគាំទ្រក្នុងក្របខណ្ឌនៃការធានាអនុវត្តតួនាទីនិងភារកិច្ចដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យនេះ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ជាអង្គភាពសម្របសម្រួលរួមក្នុងការជួយក្រសួងមុខងារសាធារណៈបំពេញតួនាទីនិងភារកិច្ចក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃ**គ.ក.រ.**។

**មាត្រា៥ ..**

ក្រសួងមុខងារសាធារណៈ អាចបង្កើតក្រុមការងារក្នុងក្របខណ្ឌក្រសួងដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈដើម្បីជួយដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនតាមការចាំបាច់។

**មាត្រា៦ ..**

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈអាចប្រគល់សិទ្ធិជូនរដ្ឋលេខាធិការប្រចាំការ ឬថ្នាក់ដឹកនាំផ្សេងទៀតនៃក្រសួងមុខងារសាធារណៈ ដើម្បីជួយដល់ការដឹកនាំនិងសម្របសម្រួលការងារក្រសួងក្នុងការបំពេញតួនាទីនិងភារកិច្ចជាលេខាធិការដ្ឋាននៃ**គ.ក.រ.**។

**មាត្រា៧ ..**

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អាចដាក់ចេញនូវសេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំ ព្រមទាំងកំណត់នូវបែបបទ នីតិវិធី និងរបៀបរបបនៃការបំពេញការងារ ដើម្បីធានាអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃ**គ.ក.រ.** ឱ្យមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី៤
## ប្រភពធនធានរបស់លេខាធិការដ្ឋាននៃគ.ក.រ.

**មាត្រា៨ ..**

ក្នុងការបំពេញតួនាទីនិងភារកិច្ចក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃ**គ.ក.រ.** ក្រសួងមុខងារសាធារណៈ អាចចាត់ចែងនិងប្រើប្រាស់នូវធនធានដែលបានពីប្រភពដូចខាងក្រោម៖

- ធនធានមនុស្ស សម្ភារៈ និងថវិកាប្រចាំឆ្នាំ របស់ក្រសួង
- ថវិកាផ្ដល់ដោយរាជរដ្ឋាភិបាល
- ធនធានស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ